របាយការណ៍សង្ខេប
ស្តីពី
លទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ
និងអគ្គលេខាធិការដ្ឋាន
អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែមីនា ឆ្នាំ២០២០

ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០

ដោយ ឯកឧត្តម **ឈឹម យិនដារ៉ែត**
អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

មាតិកា

១. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំខែកុម្ភៈ

៤. ភាពប្រឈម

៥. ជំហានបន្តសម្រាប់ខែបន្ទាប់

១.

សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

- ០៤-៥ មីនា អញ្ជើញជាអធិបតីក្នុងទិវានារី អន្តរជាតិលើកទី១០៩ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងបើកសិក្ខាសាលាពិគ្រោះយោបល់ លើការងារបង្ការទប់ស្កាត់បញ្ហាគ្រឿងញៀន-អេដស៍
- ០៧ មីនា ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារខែកុម្ភៈ និងលើកទិសដៅខែមីនា ២០២០។
- ៩ មីនា អញ្ជើញជាកិត្តិយសក្នុងពិធីសម្ពោធ បើកឱ្យប្រើប្រាស់ជាផ្លូវការ ផ្លូវជាតិលេខ ៥៥ សរុបប្រវែង ១៨២,១៦ គីឡូម៉ែត្រ និង
- ពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ១០ ពីសំឡូត (ខេត្តបាត់ដំបង)-វាលវែង (ខេត្តពោធិ៍សាត់) ទៅដល់ក្រុងខេមរភូមិន្ទ (ខេត្តកោះកុង) ប្រវែងសរុប ១៩៨,៧១ គីឡូម៉ែត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- ១៣ មីនា ជួបពិភាក្សាការងារជាមួយតំណាងអង្គការ Health Policy Plus (HP+) ស្តីអំពីយន្តការនៃកិច្ចសន្យាសេវាសង្គមនិងវឌ្ឍនភាពនៃការអនុវត្តស.ជ.ណ២១៣
- ១៤ មីនា អញ្ជើញជាកិត្តិយសក្នុងពិធីបុណ្យទន្លេ (ទន្លេនៃសន្តិភាព ទន្លេនៃវិបុលភាព) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្តម គង់ រដ្ឋា

- ពិនិត្យ ផ្តល់យោបល់ ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ការងារផ្ទៃក្នុងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីនិរន្តភាពនៃដំណើរការផ្ទៃក្នុង អ.ជ.ប.ជ.អ។

ឯកឧត្តម ង៉ា ផលា

- ប្រជុំជាមួយឯឧ កែវ អ៊ូលី Mr Bhavesh / HP+ , Dr. Srey Mony / HP+, MrUng Polin /UNAIDS នៅទីស្តីការក្រសួងផែនការស្តីពីដំណើរការផ្តល់ID Poorដល់ PLHIV at ART sites ដោយគូស algorithm ដើម្បីអោយស្របតាមតម្រូវការ PLHIV (អ្នកចង់លាក់មុខនិងអ្នកដែលមិនលាក់មុខ)ដឹកនាំកិច្ចប្រជុំជាមួយតំណាងUNAIDS team អំពីការធ្វើការវាយតម្លៃ នៃ Optima HIV Allocative Efficiency Model
- ដឹកនាំការពិក្សាជាមួយអគ្គលេខាធិការដ្ឋានអំពីការរៀបចំវិប្បសនាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ខេត្តស្ទឹងត្រែង។ចូលរួមប្រជុំគណៈកម្មាធិការសម្របសម្រួលមូលនិធិសកល (CCCឬCountry Coordination Mechanism) ស្តីអំពី Application របស់CNM for the Malaria Funding Request សម្រាប់រយៈពេល 2021-2023។បានលើកសំណួរអោយស្រាយបំភ្លឺ ការប្រើប្រាស់HCs ដើម្បីដឹកនាំ VMW meetings, outreach, surveillanceនិងការប្រើប្រាស់VMW/MMW ដើម្បីធ្វើ case management, outreachនិង forest pack distribution។

ឯកឧត្តម ទា ផល (ត)

- ចូលរួមទិវាអន្តរជាតិនារីលើកទី១០៩របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ខេត្តស្ទឹងត្រែងជួបរាយការណ៍ការងារជំនួបជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីប្រឹក្សាអង្គការUNAIDS និងឯ.ឧ. រដ្ឋលេខាធិការក្រសួងសុខាភិបាល ដល់ ឯកឧត្តមទេសរដ្ឋមន្ត្រី
- ចូលរួមវិប្បសនាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ខេត្តស្ទឹងត្រែង
- ចូលរួមដឹកនាំកិច្ចប្រជុំការងារលើកទី5របស់TWG for Fund Raising Application នៅNCHADS។
- Informal Meeting with IOM Chief Mission (Mrs. Kristen Parco) assessment on HIV and Migrant: Request for an endorsement from NAA។
- ចុះសួរសុខទុក្ខលោកJean Yves នៅទីរួមខេត្តកំពតដែលគាត់បានជួយNAAយើងក្នុងការធ្វើសមាហរណកម្មជំងឺអេដស៍នៅក្នុង CDP / CIP ក្នុងគម្រោងHP+។ (គាត់បានបាត់បង់ជើងម្ខាងដោយគ្រោះថ្នាក់ចរាចរណ៍)។

ឯកឧត្តម ជា ផលា (ត)

- ជួបសាកសួរសុខទុក្ខលោកមេឃុំត្រើយកោះ (ខេត្តកំពត) ដែលជាមេឃុំគម្រូក្នុងការឆ្លើយតបនឹងជំងឺអេដស៍ ដោយគាត់បានធ្វើការងារនេះជាង ២០ ឆ្នាំកន្លងទៅ។(អង្គការUNDPធ្លាប់បានថតដេអូអំពីការចូលរួមរបស់ឃុំគាត់កាលពីឆ្នាំ២០០០) ។ ក្នុងរយៈពេលជាង ២០ ឆ្នាំនេះនៅក្នុងឃុំត្រើយកោះមានអ្នកជំងឺអេដស៍ចំនួន ២២ នាក់ដែលបានស្លាប់និង ៩ នាក់ទៀតដែលបាននិងកំពុងប្រើថ្នាំប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ ហើយមានសុខភាពល្អនិងទទួលបានHEF(Health Equity Fund) ទាំងអស់គ្នា។
- ការចុះសួរសុខទុក្ខតាមផ្ទះដល់ក្រុមគ្រួសារដែលរងផលប៉ះពាល់ដោយជំងឺអេដស៍នៅភូមិទឹកល្អក់ឃុំត្រពាំងព្រីង ទឹកឈូខេត្តកំពត។
- រៀនសូត្រពីក្រុមគាំទ្រប្រាក់កម្ចីតាមភូមិជាមួយទឹកប្រាក់ ១២,០០០ ដុល្លារចាប់ផ្តើមពីឆ្នាំ ២០១៣ និងសមាជិក ៥០ នាក់ (គម្រោងកសិកម្ម) នៅទឹកឈូខេត្តកំពត។
- ស្វែងយល់អំពីការចូលរួមរបស់Private Sector in AIDS response at Partner in Compassions

ឯកឧត្តម ជា ផលា (ត)

- ដឹកនាំការប្រជុំ FRA (Fund Raising Application) Gfatm ជាមួយអង្គការ HACC និងCHEC ស្តីអំពី Human Rights : Enabling Environment / GBV/ Social Protection/ System Strengthening with NGOsសម្រាប់ឆ្នាំ ២០២១-២០២៣។យើងនឹងគ្របដណ្តប់លើឃុំសង្កាត់ចំនួន ៣០០ ដើម្បីឱ្យមានការរួមបញ្ចូលអេដស៍នៅក្នុង CDP/ CIP ។
- ធ្វើបទបង្ហាញFRA (Fund Raising Application) Gfatm របស់អជបជអ ដល់លោកស្រី Saba Mousavi / FRA consultant និងដៃគូពាក់ព័ន្ធនានាអង្គការ មានHACC CHEC KHANA FI UNAIDS Linkages/ FHI-360 HP+ នៅNAA។
- គោលបំណងសំខាន់នៃគម្រោងគឺដើម្បីធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងស្ថាប័នរវាងអង្គភាពរដ្ឋាភិបាល (improve institutional relationships between government entities and NGO/CBOs)ជាពិសេសអ្នកដែលដើរតួនាទីយ៉ាង សំខាន់លើការឱ្យមានបរិយាកាសគាំទ្រ,ការប្រយុទ្ធនឹងអំពើហិង្សាយេនឌ័រ និងការគាំពារសង្គមជាមួយបណ្តាញអង្គការក្រៅរដ្ឋាភិបាល / CBOs និងបុគ្គលិកមូលដ្ឋានដែលពាក់ព័ន្ធនឹងបញ្ហាទាំងនោះ (ពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ)

ឯកឧត្តម ង៉ា ផលា (ត)

- ចូលរួមប្រជុំជាមួយឯកឧត្តមប្រធានអជបជអក្នុងពេលឯកឧត្តមអនុញ្ញាត្តិអោយលោកKong Pollack /HP+ short term Consultantលើការសិក្សា Legal aspects on Social Contracting to NGO/ CBO working on HIV and AIDS in Cambodia។
- ដឹកនាំការប្រជុំ FRA (Fund Raising Application) Gfatm ជាមួយអង្គការ HACC និងCHEC ស្តីអំពី តួនាទីរបស់NGO/CBOsនៅក្នុង Proposal of NAA on Human Rights : Enabling Environment / GBV/ Social Protection/ System Strengthening សម្រាប់ឆ្នាំ ២០២១-២០២៣។
- បើកការប្រជុំបន្តស្តីពី FRA (Fund Raising Application) Gfatm ជាមួយអង្គការ HACC និងCHEC ស្តីអំពី តួនាទីរបស់NGO/CBOsនៅក្នុង Proposal of NAA on Human Rights : Enabling Environment / GBV/ Social Protection/ System Strengthening សម្រាប់ឆ្នាំ ២០២១-២០២៣។

ឯកឧត្តម ង៉ា ផលា (ត)

- ចូលរួមប្រជុំFRA TWG secretariat នៅ NCHADS ដើម្បីផ្តល់យោបល់លើសំណើសុំថវិកាមូលនិធិសកលពិ ឆ្នាំ២០២១ដល់២០២៣។ បានលើកសំណើពិនិត្យលទ្ធភាពប្រើប្រាស់ថវិកាGFATM ដើម្បីប្រយុទ្ធនឹង Coved 19 ។។
- កែសម្រួលលិខិតផ្ញើជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្នើសុំគោលការណ៍ធានាចំណាយថវិកាកម្មវិធីឆ្នាំ ២០២០ សម្រាប់បោះពុម្ពនិងការផលិតសម្ភារៈផ្សព្វផ្សាយព័ត៌មានអំពីជំងឺអេដស៍ របស់អាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ ។
- រៀបចំផលិត video រយៈពេល២០នាទីបង្ហាញ slidesដែលបរិយាយអំពី NAA FRA application ទៅមូល និធិសកលសម្រាប់ឆ្នាំ២០២១ដល់២០២៣។ videoនេះបានដាក់ជូនឯកឧត្តមប្រធាន ថ្នាក់ដឹកនាំ និងមន្ត្រី អជបជអដើម្បីស្នើយោបល់

ឯកឧត្តម ង៉ា ផលា (ត)

- ទំនាក់ទំនងជាមួយឯកឧត្តមសាស្ត្រាចារ្យអេងហួតរដ្ឋលេខាធិការក្រសួងសុខាភិបាលលើការអនុវត្តគោលនយោបាយទី៣នៃSCN 213 ពិសេសការអនុញ្ញាត្តិអោយប្រើប្រាស់ហិរញ្ញប្បទានService Delivery Grant (SDG) ដែលផ្តល់ទៅ Health Centers និង Referral Hospitals ។
- សាកសួរសុខទុក្ខលោកស្រីសានសុខាត់សមាជិកនៃ CCC(Country Coordination Mechanism)នៃមូលនិធិសកលដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ។
- ចូលរួមប្រជុំជាមួយHACC ដើម្បីសម្រួលអោយNAA FRA application អាចសហការបានជាមួយ KP/ PLHIV networks ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព។

ឯកឧត្តម ជា ផលា (ត)

- ចូលរួមពិភក្សាជាមួយក្រុម ការងារ បច្ចេកទេសដែលមានលោកវេជ្ជលីពេញស៊ុន Dr Oak Vichada / NCHADS NGO (Khanna , CRS, FI …) Development Partners (Linkages / FHI 360 , UNAIDS, Chai , CDC/ USAID, ដោយមានការចូលរួមរបស់ GF Country Team មានOlivier Covey, Brian, Mohamed ….តាមរយៈVirtual contact through Blue jeans application ដើម្បីរៀបចំផែនការប្រើប្រាស់ថវិកាGFATM រួមចំណែកប្រយុទ្ធនឹង Covid 19។ជាលទ្ធផលនៃអង្គប្រជុំNCHADS ដោយមានជំនួយការពីលោក Steve Wignall /Linkages-FHI360 នឹងរៀបចំPlanមួយដែលបញ្ជាក់ពីតម្រូវការក្នុងការរួមចំណែកប្រយុទ្ធនឹង Covid ។ផែនការនេះសង្កត់ធ្ងន់តែទៅលើ Personal Protection Equipment (Mask, alcohol, gel … សម្រាប់បុគ្គលឹកពេទ្យ NGOs/ CBOs and especially ART sites) ។អង្គការUSAID ផែនការរួមចំណែក share cost ផងដែរ។

លោកជំទាវ ស៊ឹម ខេងខាំ

- ចូលរួមប្រជុំក្នុងឱកាសអបអរសាទរខួបលើកទី១០៩ នៃទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ ២០២០ នៅខេត្តស្វាយរៀង។

- ចូលរួមសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តកម្រោងផែនការសកម្មភាព ឆ្នាំ ២០១៩ និងរៀបចំផែនការសកម្មភាពឆ្នាំ២០២០ នៅខេត្តស្វាយរៀង។

- បានពិភាក្សាជាមួយមន្ត្រីក្រុមការងារបច្ចេកទេសនៃក្រសួងកិច្ចការនារី ដើម្បីស្នើឱ្យក្រសួងនេះធ្វើរបាយការណ៍ឱ្យទាន់ ពេលវេលា ក៏ដូចជាអនុវត្តនូវសកម្មភាពស្តីពីការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ របស់សាមីក្រសួង។

ឯកឧត្តម ស៊ឹម គឹមសៃន

- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៤ ខែកុម្ភៈ ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- បានចូលរួមក្នុងសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០១៩ និងការលើកទិសដៅផែនការសកម្មភាពឆ្នាំ២០២០។
- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី១ ខែមិនា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- បានចូលរួមជាគណៈអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនយោបាយរបស់គណបក្សប្រជាជន ជូនសមាជិកបក្សនៅទីស្នាក់ការបក្សស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។
- បានអានរបាយការណ៍ស្តីពីការពង្រឹងប្រព័ន្ធឆ្លើយតបរបស់សហគមន៍ប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍របស់ HACC និង NAA
- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី២ ខែមិនា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- អានសាររបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាស្តីពីការប្រយុទ្ធនឹងជំងឺ COVID-19។

ឯកឧត្តម ស៊ឹម គឹមសៃន

- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៣ ខែមិនា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- បានអានសាររបស់ឯកឧត្តមប្រធានស្តីពីកិច្ចប្រជុំ Virtual Conference នៅក្នុង Strategy Committee របស់មូលនិធិសកល។

ឯកឧត្តម តែង គន្ធី (ត)

- ជួបពិភាក្សាជាមួយសមាជិកគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងទេសចរណ៍។

១៖ ពិភាក្សាលើការរៀបចំផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍សំរាប់អនុវត្តក្នុងឆ្នាំ ២០២០ ។

២៖ លើកទឹកចិត្ត និងជំរុញការបញ្ជៀបសារអប់រំបង្ការមេរោគអេដស៍ក្នុងឱកាសប្រារព្ធទិវាបុណ្យទន្លេនៅខេត្តបាត់ដំបង ។

៣៖ សម្របសម្រួលការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលចូលរួមផ្សព្វផ្សាយលើការងារអប់រំបង្ការមេរោគអេដស៍នាទិវាបុណ្យទន្លេនៅខេត្តបាត់ដំបង ។

ឯកឧត្តម តែង គន្ធី (ត)

- ចូលរួមវិបស្សនារបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅខេត្តស្ទឹងត្រែង

១៖ ទទួលបានទឹសដៅអនុវត្តបន្ត និង បញ្ហាប្រឈមរបស់ស្ថាប័ននៅឆ្នាំខាងមុខ។

២៖ទទួលបានព័ត៌មានស្តីពីគ្រឿងញៀន ។

៣៖ទទួលបានអនុសាសន៍ណែនាំរបស់ឯកឧត្តមប្រធានសម្រាប់ការអនុវត្តសកម្មភាពបន្តឆ្នាំ ២០២០។

ឯកឧត្តម តែង គន្ធី (ត)

- ប្រជុំ និងពិភាក្សាជាមួយអង្គការ MHC និង RACK លើការងារក្រុមបុរសរួមភេទជាមួយបុរស និងក្រុមប្លែងភេទ ។

១៖ នៅរាជធានីភ្នំពេញ តាមរយៈអង្គការ MHC ចាប់ពីថ្ងៃទី២៩ ខែកុម្ភៈដល់ថ្ងៃទី១១ ខែមីនា ក្រុមគោលដៅទំនាក់ទំនងជាមួយក្រុមបុរសរួមភេទជាមួយបុរសមកធ្វើ

- តេស្តបានចំនួន២៨ នាក់ ជាលទ្ធផលមាន HIV+ ថ្មីចំនួន ២ នាក់និងបានបញ្ជូនទៅទទួលសេវាហើយ។

២៖ក្រោមគំរោងអង្គការរ៉ាក់ផ្នែកទឹសឧត្តរ គិតចាប់ពីថ្ងៃទី ១ ខែមករា ដល់ថ្ងៃទី១០ ខែមីនាឆ្នាំ២០២០ បានអប់រំក្រុម MSM ចំនួន ៨៤៣៧ នាក់ ធ្វើតេស្តបាន ៣៥៦៥ នាក់ មានវិជ្ជមានថ្មី ៦១ នាក់ និងបញ្ជូនទៅព្យាបាល ៥៨ នាក់។

៣៖ អង្គការរ៉ាក់បន្ត និងបង្កើនការផ្តល់សេវាអប់រំផ្សព្វផ្សាយ តាមរយៈរថយន្តចល័តនៅខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ។

ឯកឧត្តម តែង គន្ធី (ត)

- ពិនិត្យការងារៀបចំគោលការណ៍ណែនាំជាតិពីការបង្ការការចម្លងមេរោគអេដស៍ជាសកល។

១៖ បានជួបពិភាក្សាជាមួយមន្ត្រីនាយកដ្ឋានជំងឺឆ្លង និងនាយកដ្ឋានមន្ទីពេទ្យរបស់ក្រសួងសុខាភិបាលដើម្បីស្វែងរកការឯកភាពគ្នាលើចំណុចកែរសំរួលខ្លឹមសារមួយចំនួន ។

២៖ ជាមតិរបស់ខាងក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គួរធ្វើគោលការណ៍ណែនាំតែលើវិស័យមិនមែនសុខាភិបាលបានហើយ ព្រោះជៀសវាងជាន់ជាមួយគោលការណ៍ណែនាំបង្ការក្នុងវិស័យសុខាភិបាល ដែលកំពុងមានសុពលភាព និងអនុវត្តរួចហើយនៅតាមគ្រប់មន្ទីរពេទ្យនៅទូទាំងប្រទេស ។

ឯកឧត្តម រស់ សីលវ៉ាត់

- ប្រជុំត្រៀម ចូលរួមទិវានារីអន្តរជាតិ និងរៀបចំវិបស្សនានៅខេត្តស្ទឹងត្រែងពិនិត្យ និងដូនយោបល់កែសម្រួលរបាយការណ៍សកម្មភាពប្រចាំខែវិច្ឆិកា ២០១៩
- ប្រជុំផ្ទៃក្នុងពិនិត្យការរៀបចំសំនើមូលនិធិសាកលលើកញ្ចប់សកម្មភាព Human Right barrier removal
- ប្រជុំបីដងជាមួយដៃគូ ពិនិត្យការរៀបចំសំនើមូលនិធិសាកលលើកញ្ចប់សកម្មភាព Human Right barrier removal

- ពិភាក្សាការងារជាមួយឯ.ឧ. អនុប្រធានទី ផលា ក្នុងការត្រៀមរៀបចំកិច្ចប្រជុំអន្តរក្រសួងពិនិត្យវឌ្ឍនភាពនៃការអនុវត្តស.ជ.ណ. ២១៣ (ដែលត្រូវបានពន្យារពេលដោយសារវិធានការទប់ទល់ការរាលដាលជំងឺកូវីដ)

ឯកឧត្តម រស់ សីលវ៉ាត់ (ឥ)

- ចូលរួមជាមួយឯ.ឧ. ប្រធានក្នុងជំនួបជាមួយអង្គការ HP+ ពិភាក្សាការងារតស៊ូមតិដើម្បីមានការផ្តល់ហិរញ្ញទានសាធារណៈដល់អង្គការសង្គមស៊ីវិលដើម្បីជួយការងារឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍
- ពិនិត្យនិងផ្តល់យោបល់កែសម្រួលរបាយការណ៍ប្រជុំបច្ចេកទេសរបស់អគ្គលេខាធិការដ្ឋាន
- ពិនិត្យនិងផ្តល់យោបល់កែសម្រួលរបាយការណ៍កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសឆ្លើយតបនឹងមេរោគអេដស៍ក្នុងចំនោមក្រុមបុរសរួមភេទជាមួយបុរស អ្នកបំលែងភេទ និងបុគ្គលិកបម្រើសេវាកម្សាន្តសប្បាយ
- ពិនិត្យនិងផ្តល់យោបល់កែសម្រួលធាតុចូលសម្រាបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាដែលដឹកនាំដោយក្រសួងផែនការ
- ចូលរួមជាមួយ ក្រុមការងារ PEPFAR ក្នុងកិច្ចពិភាក្សាថ្នាក់ជាតិរៀបចំគម្រោងសំណើថវិកាតំបន់ (ROP) របស់ PEPFAR សម្រាប់ឆ្នាំ២០២០

ឯកឧត្តម រស់ សីលវ៉ាត់ (ឥ)

- ចូលរួមប្រជុំក្រុមការងារចម្រុះរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ពិនិត្យការប្តូរវេននៃសហប្រធានពីខាងដៃគូ កែសម្រួល តួនាទីភារកិច្ចរបស់ក្រុមការងារជាថ្មី ការត្រៀមចូលរួមធ្វើសំនើថវិកាមូលនិធិសាកលជុំថ្មី ការដាក់ស្នើរបស់ អ.ជ.ប.ជ.អ
- ចូលរួមជាមួយឯ.ឧ. អនុប្រធានទា ផលា ទទួលជួបជាមួយទីប្រឹក្សាបច្ចេកទេសអង្គការ FHI360 ពីការិយាល័យកណ្តាលនៅសហរដ្ឋអាមេរិក ស្វែងយល់ពីឧបសគ្គនានាជាពិសេសតម្រូវការសក្តីកម្មសម្រាប់គាំទ្រដល់វិធីសាស្ត្រផ្សេងៗ ក្នុងទិសដៅឆ្ពោះទៅរក្សាចីរភាពនៃការងារប្រយុទ្ធនឹងជំងឺអេដស៍
- ចូលរួមជាមួយគណៈកម្មការសម្របសម្រួលថ្នាក់ប្រទេសនៃមូលនិធិសកល ក្នុងកិច្ចពិភាក្សាថ្នាក់ប្រទេសស្តីពីការរៀបចំគម្រោងសំណើថវិកាមូលនិធិសកលជុំថ្មី ២០២១ ដល់២០២៣
- ដឹកនាំកិច្ចប្រជុំជាមួយមន្ត្រីជំនាញធ្វើសេចក្តីព្រាងផែនការវិនិយោគបីឆ្នាំរំកិល ២០២១ ដល់២០២៣ របស់ អ.ជ.ប.ជ.អ

ឯកឧត្តម ជា ពៅ

- ចូលរួមអបអរសាទរទិវាអន្តរជាតិនារី លើកទី១០៩ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្រោមប្រធានបទ "មានសន្តិភាព មានការលើកកម្ពស់សមភាពយេនឌ័រ" នៅខេត្តស្ទឹងត្រែង
- សិក្ខាសាលាស្តីពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព និងសមិទ្ធិផលនៃការអនុវត្តគម្រោងផែនការសកម្មភាព ឆ្នាំ២០១៩ និងការរៀបចំផែនការសកម្មភាពឆ្នាំ២០២០ រយៈពេល២ថ្ងៃ នៅខេត្តស្ទឹងត្រែង។
- តាមដាន និងស្រាវជ្រាវឯកសារសម្រាប់ទប់ស្កាត់ការឆ្លង និងចម្លងមេរោគកូរ៉ូណា ១៩ ដើម្បីផុសក្នុងហ្វេសបុកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បន្តតាមដាន និងស្រាវជ្រាវឯកសារសម្រាប់ទប់ស្កាត់ការឆ្លង និងចម្លងមេរោគកូរ៉ូណា ១៩ ដើម្បីផុសក្នុងហ្វេសបុកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានផុសក្នុងហ្វេសបុកផេកសរុបចំនួន ១៨ដង ទាក់ទងCovid-19 ក្នុងខែមីនា
- បានផុសក្នុងហ្វេសបុកផេកសរុបចំនួន ២៣ដង ក្នុងខែមីនា

ឯកឧត្តម ហោ ប៊ុនឆ្លេច

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៤ ខែកុម្ភៈ ប្រចាំខែ២០១២របស់អគ្គលេខាធិការដ្ឋាន
- ពិនិត្យរបាយការណ៍កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែកុម្ភៈ ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានចូលរួមសិក្ខាសាលាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅខេត្តស្ទឹងត្រែង ដើម្បីពិនិត្យទៅលើសមិទ្ធផលឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០។
- បានពិនិត្យទៅលើរបាយការណ៍កិច្ចប្រជុំ FRA។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី១ ខែមិនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន
- បានចូលរួមកិច្ចប្រជុំរៀបចំរបាយការណ៍វឌ្ឍនៈភាព និងសមិទ្ធផលប្រចាំត្រីមាសទី១ឆ្នាំ២០២០ របស់ឥស្សរជនឆ្នើមថ្នាក់ជាតិ ។
- បានពិនិត្យទៅលើរបាយការណ៍កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិរបស់ប្រជាជនគន្លឹះឆ្នាំ២០២០ ។
- បានចូលរួមកិច្ចប្រជុំជាមួយក្រសួងកិច្ចការនារីលើការងារ កសាងសមត្ថភាព បញ្ជ្រាប និងបញ្ចូលយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រ។

ឯកឧត្តម ហោ ប៊ុនឡេង (ឥ)

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី២ខែមិនាឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- បានទទួលការងាររៀបចំរបាយការណ៍ប្រចាំត្រីមាសទី១ឆ្នាំ២០២០ របស់ក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិ។
- បានទទួលភារកិច្ចជាគ្រូបណ្តុះបណ្តាលស្តីពីកសាងសមត្ថភាព បញ្ជ្រាប និងបញ្ចូលយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រ។
- បានទៅចូលរួមជាអធិបតីក្នុងពិធីបើកវគ្គបំពាក់បំប៉ននយោបាយនៅគណបក្សស្រុកបសេដ្ឋ។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៣ខែមិនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន
- បានចូលរួមកិច្ចប្រជុំរៀបចំផែនការសកម្មភាពរបស់ក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិប្រចាំត្រីមាសទី២ឆ្នាំ២០២០។
- បានរៀបចំបញ្ចប់ឯកសារបណ្តុះបណ្តាលស្តីពីកសាងសមត្ថភាព បញ្ជ្រាប និងបញ្ចូលយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រ។

ឯកឧត្តម ស៊ឹម គឹមសាន

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៤ ប្រចាំ ខែ កុម្ភៈ ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន
- ពិនិត្យរបាយការណ៍កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែកុម្ភៈ ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ចូលរួមការប្រារព្ធទិវាអន្តរជាតិនារី លើកទី១០៩ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមប្រធានបទ មានសន្តិភាព មានការលើកកម្ពស់សមភាពយេនឌ័រ នៅខេត្តស្ទឹងត្រែង ។
- ចូលរួមសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តគម្រោងផែនការសកម្មភាពឆ្នាំ២០១៩ និងការរៀបចំផែនការសកម្មភាពឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅខេត្តស្ទឹងត្រែង ។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី១ ខែ មីនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន ។

ឯកឧត្តម ហោ ប៊ុនឡេង

- អានរបាយការណ៍ស្តីពីការពង្រឹងប្រព័ន្ធឆ្លើយតបរបស់សហគមន៍ប្រយុទ្ធនឹងជំងឺអេដស៍របស់HACC& NAA
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី២ខែមីនា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន ។
- បានអានដោយយកចិត្តទុកដាក់នូវសាររបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រយុទ្ធនឹងជំងឺ Covid-19 ។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៣ខែ មីនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន ។
- អានដោយយកចិត្តទុកដាក់ខ្ពស់នូវសាររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ស្តីពីកិច្ចប្រជុំ Virtual Conference នៅក្នុង Strategy committee របស់ មូលនិធិសកល ។
- បានពិនិត្យទៅលើសេចក្តីព្រាងស្តីពីការរៀបចំសិក្ខាសាលាស្តីពីការលើកទិសដៅផែនការសកម្មភាពរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២០ ដែលនឹងប្រព្រឹត្តទៅនៅខេត្តស្វាយរៀង។

២.

សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការ

- ព្រឹកថ្ងៃទី០២ ខែមីនា ដឹកនាំកិច្ចប្រជុំសម្រាប់រៀបចំទិវាអន្តរជាតិនារី ៨មីនា និងសិក្ខាសាលាស្តីពីការពិគ្រោះយោបល់លើការងារដែលបានអនុវត្តក្នុងឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ ដើម្បីអនុវត្តបន្ត នៅខេត្តស្ទឹងត្រែង។
- ថ្ងៃទី០៣ ដល់ទី០៦ ខែមីនា ចូលរួម ទិវានារីអន្តរជាតិ០៨ មីនា និងសិក្ខាសាលាស្តីពីការពិគ្រោះយោបល់លើការងារដែលបានអនុវត្តក្នុងឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ ដើម្បីអនុវត្តបន្ត នៅខេត្តស្ទឹងត្រែង។
- ព្រឹកថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ បានដឹកនាំកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍
- ថ្ងៃទី១០ ខែមីនា ដឹកនាំកិច្ចប្រជុំ ដែលឧបត្ថម្ភដោយមូលនិធិសកល
- ថ្ងៃទី១២-១៣ ខែមីនា បើកវគ្គបណ្តុះ បណ្តាលស្តីពីបរិយាកាសគាំទ្រ ច្បាប់ និងគោលនយោបាយ ក្នុងការគាំទ្រឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ដល់ថ្នាក់ក្រោមជាតិ នៅសណ្ឋាគារសាន់វេ
- ព្រឹកថ្ងៃទី១៣ ខែមីនា ដឹកនាំកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសស្នាក់ជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងចំណោម ប្រជាជនប្រឈម។

អគ្គលេខាធិការ (ត)

- ព្រឹកថ្ងៃទី១៣ ខែមីនា ចូលរួមជំនួបពិភាក្សាការងាររវាងឯកឧត្តមទេសរដ្ឋមន្ត្រី ជាមួយអង្គការHP+ អំពីលទ្ធភាពនៃការផ្តល់ថវិកាដល់អង្គការសង្គមស៊ីវិល។
- ព្រឹកថ្ងៃទី១៦ ខែមីនា ដឹកនាំកិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍។
- ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ឯកឧត្តមអគ្គលេខាធិការបានចូលរួមប្រជុំបញ្ជៀសការឆ្លងជំងឺកូវីត ១៩ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- រៀបចំសេចក្តីព្រាងទស្សនទានស្តីការរៀបចំធ្វើសមាហរណកម្ម កម្មវិធីអេដស៍ ទៅក្នុងផែនការអភិវឌ្ឍថ្នាក់ឃុំ ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ
- ដឹកនាំការងារប្រតិបត្តិការប្រចាំថ្ងៃរបស់នាយកដ្ឋានទាំងបួនក្រោមអគ្គលេខាធិការដ្ឋាន
- ពិនិត្យផ្តល់យោបល់ និងលើកសំណើលើការងារបច្ចេកទេស រដ្ឋបាល ហិរញ្ញវត្ថុ និងនយោបាយជូន ឯកឧត្តមទេសរដ្ឋមន្ត្រី។

អគ្គលេខាធិការដ្ឋាន

ឯកឧត្តម លោកជំទាវអគ្គលេខាធិការដ្ឋានទាំងបួនរូប បានបំពេញការងារជួយ អគ្គលេខាធិការ តាមការបែងចែកភារកិច្ច និងមានសកម្មភាព លទ្ធផលការងារដូចក្នុងរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ ដែលបានគោរពជូន បានត្រឹមត្រូវ។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

I. ការងាររដ្ឋបាល និងបុគ្គលិក

១. បានចូលរួមប្រជុំរួមប្រចាំសប្តាហ៍អគ្គលេខាធិការដ្ឋានចំនួន ០២លើក គឺនៅថ្ងៃទី៩ និង១៦ ខែមីនា ឆ្នាំ២០២០។

២. បានប្រជុំប្រចាំសប្តាហ៍នាយកដ្ឋានចំនួន០៣ដង គឺនៅថ្ងៃទី២ ១០ និង១៦ ខែមីនា ខែមីនា ឆ្នាំ២០២០ ដើម្បីពិនិត្យ មើលការងារដែលបានអនុវត្ត និងដាក់ផែនការអនុវត្តបន្ត។

៣. បានចូលរួមរៀបចំសិក្ខាសាលាយេនឌ័រ នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២០ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤. បានរៀបចំទិវាអន្តរជាតិនារី ៨មីនា និងសិក្ខាសាលាស្តីពីការលើកទិសដៅផែនការសកម្មភាព ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី៣-៥ ខែ មីនា ឆ្នាំ២០២០ នៅខេត្តស្ទឹងត្រែងដោយជោគជ័យ។

៥. បានចូលរួមកិច្ចប្រជុំពិភាក្សាអំពី ការដាក់សំណើសុំថវិកាមូលនិធិសកលសម្រាប់ឆ្នាំ២០២១-២០២៣ ក្រោមអធិបតីភាពឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា ដោយមានការ ចូលរួមពីអង្គការដៃគូពាក់ព័ន្ធរួមមាន UNAIDS KHANA HACC HP+ ... និងទីប្រឹក្សាបច្ចេកទេស។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ (ត)

៦. មន្ត្រីជំនាញក្រសួងសុខាភិបាលបានបញ្ចូលប្រាក់ខែក្នុងគណនីឯកឧត្តម ង៉ាក់ ប៊ុនធី និងប្រាក់តួនាទីជូនថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ ២៣រូបដែលទើបតែងតាំង រួចរាល់នៅក្នុងខែមីនា។

៧. បានចូលរួមប្រជុំស្តីពីការឆ្លើយតបនឹងការរីករាលដាលCOVID-19 នៅថ្ងៃទី១៨ ខែមីនា ក្រោមអធិបតីភាពឯកឧត្តមអនុប្រធានប្រចាំការ។

៨. បានសហការជាមួយនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវកំណត់វាក្យសព្ទស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ចំនួន ១៤៧ពាក្យ។

៩. រៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការចាត់តាំងក្រុមប្រឹក្សាបច្ចេកទេស។

១០. បានធ្វើបញ្ជីរាយនាមមន្ត្រីជាប់កិច្ចសន្យាឆ្នាំ២០២០ដែលជានិវត្តន៍ជនបញ្ជូនទៅ ក្រសួងសុខាភិបាលដើម្បីទទួលបានប្រាក់ឧបត្ថម្ភក្នុងពិធីបុណ្យចូលឆ្នាំថ្មីពីរាជរដ្ឋាភិបាល។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ (ត)

II. ការងារផ្គត់ផ្គង់ គណនេយ្យ និងហិរញ្ញវត្ថុ

១. បានផ្គត់ផ្គង់សម្ភារ និងបរិក្ខារសម្រាប់ដំណើរការរៀបចំទិវាអន្តរជាតិនារី ៨មីនា និងសិក្ខាសាលាស្តីពីការលើកទិសដៅផែនការសកម្មភាព ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី៣-៥ ខែមីនា ឆ្នាំ២០២០ នៅខេត្តស្ទឹងត្រែង។

២. រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំគោល ឆ្នាំ២០១៩។

៣. បានបង្វៃសាច់ប្រាក់ចូលក្នុងគណនីលើបេសកកម្មក្នុងស្រុកចំនួន ៤៩ ដែលបានធ្វើពីដើមឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ ដែលមានសាច់ប្រាក់ចំនួន១៣១.៤១៧.៤០០រៀល រួចរាល់នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២០។

៤. បានរៀបចំឯកសារស្នើសុំទូទាត់ត្រង់បេសកកម្មក្នុងប្រទេស ដែលបានធ្វើពីថ្ងៃទី២០ ខែវិច្ឆិកា ២០១៩ ដល់ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ មានថវិកាសរុប ៥៨.៧២៣.៦០០រៀល និងបញ្ជូនចេញទៅអភិបាលហិរញ្ញវត្ថុក្រសួងសុខាភិបាល។

៥. បានរៀបចំឯកសារស្នើសុំទូទាត់បេសកកម្មក្នុងប្រទេស តាមរដ្ឋទេយ្យ ដែលបានធ្វើពីថ្ងៃទី០៣ ខែមករា ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ មានថវិកាសរុបចំនួន ១៥៥.១៤៩.៤០០ ទៅអភិបាលហិរញ្ញវត្ថុក្រសួងសុខាភិបាល។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ (ត)

៦. បានបញ្ចប់ការទូទាត់ការចំណាយលើការរៀបចំសិក្ខាសាលាចំនួន២គឺ ៖ ១) សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងនីតិវិធីរដ្ឋបាលដល់មន្ត្រី និងមន្ត្រីជាប់កិច្ចសន្យា ២) សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ៣) សិក្ខាសាលាក្រុមប្រឹក្សាបច្ចេកទេសលើកទី២ ឆ្នាំ២០២០។

៧. បានរៀបចំឯកសារស្នើសុំឥណទានថវិកាតាមកម្មវិធីជំពូក៦១ សម្រាប់ទូទាត់ប្រាក់បេសកកម្មក្នុងប្រទេសជូន មន្ត្រី អ.ជ.ប.ជ.អ ពីថ្ងៃទី២០ ខែវិច្ឆិកា ២០១៩ ដល់ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០។

៨. បានរៀបចំឯកសារស្នើសុំទូទាត់ចំណាយថវិការដ្ឋទេយ្យប្បុរេប្រទានតាមកម្មវិធី ជំពូក៦១. សម្រាប់ទូទាត់ប្រាក់បេសកកម្មក្នុងប្រទេសជូនមន្ត្រីអ.ជ.ប.ជ.អ ពីថ្ងៃទី០៣ ខែមករា ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០

៩. បានរៀបចំឯកសារស្នើសុំឥណទានថវិកាតាមកម្មវិធីជំពូក៦១ សម្រាប់ទូទាត់ថ្លៃប្រើប្រាស់ទូរស័ព្ទអចល័តរបស់ អ.ជ.ប.ជ.អ ជូនទូរគមនាគមន៍កម្ពុជា ពីខែធ្នូ ឆ្នាំ២០១៩ ដល់ខែកុម្ភៈ ឆ្នាំ២០២០។

១០. បានរៀបចំបណ្ណចំណាយបន្ទាន់ចាំបាច់ផ្ទៃក្នុងរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួន១៧ច្បាប់។

១១. បានចាត់ចែងការចុះបញ្ជីបេឡាសាច់ប្រាក់ក្នុងធនាគារ និងក្នុងដៃសម្រាប់ខែមីនា។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

១២. បានដកសាច់ប្រាក់ពីធនាគារជាតិចំនួន ៤៤.០០០.០០០រៀល សម្រាប់យកមកចំណាយដំណើរការចាំបាច់ និងបន្ទាន់នៅក្នុងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

១៣. បានរៀបចំបណ្ណាស្នើសុំដកប្រាក់ចំនួន២០ភាគរយនៃជុំថវិការដ្ឋទេយ្យបុរេប្រទាន ឆ្នាំ២០២០ ពីអគ្គនាយកដ្ឋានរតនាគារជាតិ ចំនួន ១២.៦១៥.៤០០រៀល។

១៤. បានបញ្ចប់ការងារស្នើសុំបង្កើតជុំរដ្ឋទេយ្យបុរេប្រទានឆ្នាំ២០២០ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៥. បានបញ្ចប់ការធ្វើងផ្ទាត់ជម្រះឯកសារបិទបញ្ជីការលើឯកសារហិរញ្ញវត្ថុឆ្នាំ២០១៩។

១៦. ពិនិត្យ និងអនុម័តតារាងឧបសម្ព័ន្ធថវិការដ្ឋទេយ្យបុរេប្រទានតាមប្រព័ន្ធ FMIS។

១៧. បន្តតាមដានឯកសារស្នើសុំគោលការណ៍ធានាចំណាយឆ្នាំ២០២០ ចំនួន៤រួមមាន ៖ ១) សម្ភារអប់រំផ្សព្វផ្សាយអំពីមេរោគអេដស៍ និងជំងឺអេដស៍ ២) ប្រេងឥន្ធនៈ និងប្រេងរំអិល ៣) បេសកកម្មក្រៅប្រទេស និង៤) ការបោះពុម្ព។

១៨. បានពិនិត្យ និងចុះហត្ថលេខាទៅលើការចំណាយរបស់ថវិកាជំនួយ Global Fund ចំនួន១៤ច្បាប់។

ឆាយកដ្ឋានឆាក់ឆង និងចលនាប្រភពធនធាន

១. បានរៀបចំប្រជុំក្រុមប្រឹក្សាបច្ចេកទេស ស្តីពីការរៀបចំផែនការសកម្មភាពតាមក្រសួង ស្ថាប័ន ជាសមាជិក។

២. បានបញ្ចប់របាយការណ៍ប្រជុំក្រុមប្រឹក្សាបច្ចេកទេស ស្តីពីការរៀបចំផែនការ សកម្មភាពតាមក្រសួង ស្ថាប័ន ជាសមាជិក។

៣. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ បានចូលរួមពិធីអបអរសាទរខួបលើកទី១០៩ ទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ ២០២០ នៅខេត្តស្ទឹងត្រែង។

៤. នៅថ្ងៃទី០៤-០៥ ខែមីនា ឆ្នាំ២០២០ បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព សមិទ្ធ ផលនៃការអនុវត្តគម្រោងផែនការសកម្មភាពឆ្នាំ២០១៩ និងការរៀបចំផែនការសកម្មភាពឆ្នាំ២០២០ របស់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅខេត្តស្ទឹងត្រែង។

៥. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់គុណភាពសេវា បង្ការ ថែទាំ ព្យាបាលអ្នករស់នៅជាមួយមេរោគអេដស៍នៅរាជធានីភ្នំពេញ។

ឆាយកដ្ឋានឆាក់ឆេ និងចលនាប្រភពធនធាន

៦. នៅថ្ងៃទី១៦–១៩ ខែកុម្ភៈ ឆ្នាំ២០២០ បានចុះអភិបាលការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅខេត្តពោធិ៍សាត់។

៧. បានចូលរួមប្រជុំ ស្តីពីវិធានអនាម័យដើម្បីបង្ការការចម្លងជំងឺកូវីដ១៩ នៅកន្លែងធ្វើការ។

៨. បានចាត់មន្ត្រីចូលរួមប្រចាំការជាមួយការិយាល័យរបៀប តាមការសម្រេចរបស់កិច្ចប្រជុំស្តីពីវិធានអនាម័យនៅកន្លែងធ្វើការ។

៩. បានសម្របសម្រួលរៀបចំបញ្ជីឈ្មោះអ្នកជំងឺរ៉ាំរ៉ៃ បញ្ជូនទៅក្រសួងផែនការ ដាក់បញ្ចូលក្នុងការចងក្រងបញ្ជីអាទិភាពដើម្បីសំភាស៍ផ្តល់ប័ណ្ណសមធម៌។

នាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ

១. នៅថ្ងៃទី១៣ និងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ បានប្រជុំប្រចាំខែក្នុងនាយកដ្ឋាន០២លើក និងបានរៀបចំផែនការរបស់នាយកដ្ឋាន ដើម្បី លើកផែនការសកម្មភាពសម្រាបអនុវត្តបន្ត និងពង្រឹងការកិច្ចទទួលខុសត្រូវរបស់មន្ត្រីក្នុងនាយកដ្ឋាន។

២. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ បានចូលរួមពិធីអបអរសាទរខួបលើកទី១០៩ ទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ ២០២០ នៅខេត្តស្ទឹងត្រែង។

៣. នៅថ្ងៃទី០៤-០៥ ខែមីនា ឆ្នាំ២០២០ បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព សមិទ្ធផលនៃការអនុវត្តគម្រោងផែនការសកម្មភាពឆ្នាំ២០១៩ និងការរៀបចំផែនការសកម្មភាពឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅខេត្តស្ទឹងត្រែង។

៤. នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ បានរៀបចំប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសរបស់ MSM/TG និង FEW(០១លើក)។

៥. បានធ្វើការប្រមូលទិន្នន័យពីក្រុមប្រជាជនគន្លឹះ ដើម្បីបានព័ត៌មានថ្មីៗពីចំនួន KP, PLHIV, VCCT, MSM/TG, FEW។

៦. បានចូលរួមប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ និងប្រចាំខែ (ថ្ងៃទី០៩ និងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០) ដឹកនាំកិច្ចប្រជុំដោយឯកឧត្តមអគ្គលេខាធិការ។

ឥរិយាបថរបស់ថ្នាក់ដឹកនាំ និងគាំទ្រ (ត)

៧. នៅថ្ងៃទី១០-១១ ខែមីនា ឆ្នាំ២០២០ បានចុះអភិបាលការងារឆ្លើយតបមេរោគអេដស៍តាមរយៈដៃគូសហគមន៍ នៅខេត្តប៉ៃលិន និងខេត្តកំពង់ធំ ដោយមានគោលបំណងដូចអាទិ៍៖

- ផ្តល់ការតម្រង់ទិសនិងលើកសកម្មភាពគន្លឹះៗសំរាប់អនុវត្តការងារអេដស៍នៅថ្នាក់ខេត្ត និងការអនុវត្ត គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព
- បង្កើនកិច្ចសហការរវាង អ្នកផ្តល់សេវានិងអាជ្ញាធរ ដែនដី
- លើកទឹកចិត្តដល់ PAS/PAC, PAO ជួយជម្រុញបន្ថែម អោយបានខ្លាំងក្លាក្នុងការលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០៣០

៨. បានពិនិត្យ និងកែសម្រួល អោយប្រសើរឡើង ពីគោលការណ៍ណែនាំស្តីពីការការពារមេរោគអេដស៍ជាសកល៖ បានកែរសម្រួល តាមអនុសាសន៍ណែនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីបានដាក់ជូន **ឯកឧត្តមអនុប្រធាន តែង គន្ធី** ពិនិត្យ និងផ្តល់អនុសាសន៍

៩. បានរៀបចំ និងពិនិត្យឡើងវិញ លើប្លង់មេរៀន សម្រាប់ធ្វើការបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីបរិយាកាសគាំទ្រ និងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តាមរយៈដៃគូសហគមន៍៖

- បានពិនិត្យកែសម្រួលវិធីសាស្ត្រ និងខ្លឹមសារមេរៀន
- ធ្វើអោយប្រសើរថែមទៀតនូវគុណភាពស្លាយបង្ហាញ
- ពិនិត្យពេលម៉ោង អោយបានសមស្រប ជ្រើសរើសវីដេអូ និងខ្លឹមសារវីដេអូឃ្លីប សម្រាប់អប់រំបន្ត

ឆាយកដ្ឋានបន្ថែម ថែទាំ និងគាំទ្រ

១០. បានប្រជុំរៀបចំផែនការនាយកដ្ឋាន សម្រាប់អនុវត្តសកម្មភាពរបស់មូលនិធិសកល ត្រីមាសទី២ និងទី៣ ឆ្នាំ២០២០។

១១. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីការបង្កបរិយាកាសអំណោយផលសម្រាប់ក្រុមប្រជាជនគន្លឹះក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ខេត្ត និងរាជធានីនៅសណ្ឋាគារសាន់វ៉េ ។

១២. បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលពី EE-MCPI-DD សម្រាប់ខេត្តស្វាយរៀង (ថ្ងៃទី ១៨ ដល់ទី២០ ឆ្នាំ២០២០) និងខេត្តសៀមរាប (ថ្ងៃទី២៣ ដល់ទី២៥ ឆ្នាំ២០២០)។

១៣. បានរៀបចំរបាយការណ៍កិច្ចប្រជុំផ្សេងៗ សម្រាប់អគ្គលេខាធិការដ្ឋានថ្នាក់ដឹកនាំ និងដៃគូពាក់ពន្ធ័។

នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

១. បានចូលរួម និងធ្វើកំណត់ហេតុក្នុងកិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ក្រោមការដឹកនាំកិច្ចប្រជុំដោយឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ បានចូលរួមកិច្ចប្រជុំ ស្តីពីការត្រៀមរៀបចំពិធីអបអរសាទរខួបលើកទី១០៩ ទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ២០២០ និងការពិនិត្យឡើងវិញនូវវឌ្ឍនភាព សមិទ្ធផលនៃការអនុវត្តគម្រោងផែនការសកម្មភាពឆ្នាំ២០១៩ និងការរៀបចំផែនការសកម្មភាព ឆ្នាំ២០២០ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣. នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ បានចូលរួមពិធីអបអរសាទរខួបលើកទី១០៩ ទិវាអន្តរជាតិនារី ០៨ មីនា ឆ្នាំ២០២០ នៅខេត្តស្ទឹងត្រែង។

៤. នៅថ្ងៃទី០៤-០៥ ខែមីនា ឆ្នាំ២០២០ បានចូលរួមរៀបចំសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព សមិទ្ធផលនៃការអនុវត្តគម្រោងផែនការសកម្មភាពឆ្នាំ២០១៩ និងការរៀបចំផែនការសកម្មភាពឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅខេត្តស្ទឹងត្រែង។

នាយកដ្ឋានផែនការ ត្រួតពិនិត្យ ទាយតម្លៃ និងស្រាវជ្រាវ (ក)

៥. នៅព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ បានរៀបចំកិច្ចប្រជុំ ស្តីពីក្រុមការងារបច្ចេកទេសអនុវត្តគម្រោងដែលទាក់ទងនឹងអំពើហិង្សាយេនឌ័រ និងមេរោគអេដស៍ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៦. ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់ក្រសួងស្ថាប័ន នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៧. នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ បានចូលរួមក្នុងកិច្ចប្រជុំសិក្សាពីតម្រូវការក្នុងការអនុវត្តការងារ ស្តីពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (Costing) ។

៨. នៅថ្ងៃទី១២-១៣ ខែមីនា ឆ្នាំ២០២០ បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីបរិយាកាសគាំទ្រ ច្បាប់ និងគោលនយោបាយ ក្នុងការគាំទ្រឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ដល់មន្ត្រីថ្នាក់ក្រោមជាតិ នៅសណ្ឋាគារសាន់វ៉ែ។

៩. បានបញ្ចប់ការបូកសរុបរបាយការណ៍សកម្មភាព របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែកុម្ភៈ ឆ្នាំ២០២០។

១០. បានបញ្ចប់របាយការណ៍ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (NSPV)។

ឆាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ (ក)

១១. បានបញ្ចប់ការរៀបចំឆាតុចូលសម្រាប់របាយការណ៍ ស្តីពីការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ ២០១៩-២០២៣ ដែលសម្របសម្រួលដោយក្រសួងផែនការ។

១២. បានរៀបចំផែនការវិនិយោគសាធារណៈ ៣ឆ្នាំរំកិល (PIP) ឆ្នាំ២០២១-២០២៣ ដើម្បីដាក់ជូនក្រសួងផែនការ ។

១៣. បានចូលរួមប្រជុំពិភាក្សាការងារជាមួយទីប្រឹក្សាព័ត៌មានយុទ្ធសាស្ត្រ UNAIDS ស្តីពីការរៀបចំរបាយការណ៍ត្រួតពិនិត្យអេដស៍សកល ឆ្នាំ២០១៩ Globle AIDS Monitoring GAM 2019។

១៤. បានរៀបចំធ្វើវាក្យស័ព្ទស្តីពីមេរោគអេដស៍ និងជំងឺអេដស៦សម្រាប់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

១៥. ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ បានចូលរួមកិច្ចប្រជុំ ស្តីពីវិធានអនាម័យ និងការបញ្ឈៀសការឆ្លងជំងឺ Covid-19 នៅក្នុងស្ថាប័នអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

១៦. បានកែសម្រួលរបាយការណ៍សកម្មភាព របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែមករា ឆ្នាំ ២០២០។

នាយកដ្ឋានផែនការ ត្រួតពិនិត្យ ទាយតម្លៃ និងស្ថាវជ្រាវ

១៨. បានចងក្រង ពិនិត្យ និងកែសម្រួល នូវរបាយការណ៍សកម្មភាពរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែមីនា ឆ្នាំ២០២០។

១៩. បានបញ្ចប់ក្នុងការរៀបចំធ្វើបញ្ជីសារពើភ័ណ្ឌសម្រាប់ឆ្នាំថ្មី និងបានប្រគល់ជូនទៅការិយាល័យផ្គត់ផ្គង់ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរួចរាល់។

២០. បានចាត់មន្ត្រីទៅប្រចាំការនៅខាងមុខ ជាមួយខាងការិយាល័យរដ្ឋបាល-រៀប តាមការសម្រេចរបស់កិច្ចប្រជុំ ស្តីពីវិធានអនាម័យនៅកន្លែងធ្វើការ។

Activities Report Quarter 1

Jan- March

Activities conducted (1)

Conducted 1 quarterly meeting[1] on MCPI/EE and D&D TWG (at central level with participation of provincial representatives)- activity related to stigma reduction.

Conduct 1 training on MCPI and D&D for 40 communes in selected provinces in Svay Rieng

Conducted 2 Supervision (quarterly) on MCPI/D&D implementation at provincial and districts level to Pailin and Kampong thom.

Activities conducted (2)

Organized meeting on Prey Speu center/Rehabilitation center to improve access to health service to improve the KP access to health service_held at NAA.

Conducted the Supervision on HIV/AIDS response in the hot-spots provinces (Pusrat and Prah Vihear)

Organize 1 training is to provide knowledge on MCPI, CDP/CIP, GBV and enabling environment for implementing the HIV/AIDS activities MCPI for police, commune council; Health officers and KPs was held in P. Penh (at Sunway hotel)

Activities conducted_3

Organized a meeting technical working group to lead the changes, analysis issues, make recommendation /and follow up on GBV and GBV related for KP held at NAA

Organized an orientation workshop for EE owners and EWs for the awareness and implementation of the new ministerial regulations of the MoLVT (Prakas 086 and 194). At DpLVT , Siem Reap

Conducted 2 supervision (quarterly) on MCPI/D&D implementation at provincial and districts level (Pailin and Kampong Thom provinces).

Activities that **were not** organized

Due to the COVID-19 there are some activities could not conducted

- 2 Supervisions were not conduct.
- 1 coordination meeting was not organized
- 1 training on MCPI was not organized
- 3 meetings at provincial under responsible of MoLVT were not organized

Activities plan for April

Activities	# of visits	Remarks
301-8 To conduct the Supervision on HIV/AIDS response in the hot-spots provinces	4	Pailin and Kep Kampong Cham
BL#89_Supervision (quarterly) on MCPI/D&D implementation at provincial and districts level	2	Kampot;

Activities plan for April (con't)

Activities	# of activities	Remarks
Organized meeting on Prey Speu center/Rehabilitation center to improve access to health service to improve the KP access to health service held at NAA.	1	At NAA
Organized a meeting technical working group to lead the changes, analysis issues, make recommendation /and follow up on GBV and GBV related for KP _ held at NAA	1	at NAA
	2	at NAA

Expenditure for Q1

- Budget spent for march : 8,577.00 USD
- Budget spent for Q1(Jan-March): 13,293.00 USD (68.34%)

Due to the COVID-19 there are some activities could not conducted

- 2 Supervisions were not conduct.
- 1 coordination meeting was not organized
- 1 training on MCPI was not organized
- 3 meetings at provincial under responsible of MoLVT were not organized

2018	**2019**	Q9	Q10	Q11	Q12	**2020**	**Total**
41,403.67	**96,706.27**	19,450.50	19,450.50	19,450.50	19,132.50	**77,484.00**	**215,593.94**

Proposed Budget 2021-23

Description	Budget (in USD)			
	Y1	**Y2**	**Y3**	**Total**
Core Activities				
I-MCPI (Most AT risk Population Community Program Initiative and building and improving Enabling Environment)	6,770	6,770	-	13,540
II. Gender Based Violence (GBV)	8,380	8,380	-	16,760
III. CIP/CDP: This component is about to assist commune council to develop HIV AIDS plan	64,295	80,303	85,906	230,504
IV. Grant management, Administrative and running Cost	25,146	25,346	27,346	77,838
Total	**104,591**	**120,799**	**113,252**	**338,642**
Prioritized Above Allocative Request (PAAR)				
III. CIP/CDP: This component is about to assist commune council to develop HIV AIDS plan (PAAR)		69,235	93,352	162,587
Total	**-**	**69,235**	**93,352.00**	**162,587**
Grand total	**104,591**	**190,034**	**206,604**	**501,229**

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ខែមីនា

- បានរៀបចំផែនការវិនិយោគសាធារណៈ ៣ឆ្នាំរំកិល សម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ ២០២១-២០២៣ ផ្ញើជូនក្រសួងផែនការរួចរាល់។

ចំណាយប៉ាន់ស្មាន (ដុល្លារ)				ហិរញ្ញប្បទានដែលសន្យាផ្តល់(ដុល្លារ)					តម្រូវការហិញ្ញប្បទានបំពេញបន្ថែម (ដុល្លារ)			
2021	2022	2023	សរុប	ប្រភពទុន	2021	2022	2023	សរុប	2021	2022	2023	សរុប
25,600	27,500	27,200	80,300									
				RGC	2,700	3,200	5,700	11,600	0	0	0	0
				GF	13,800	13,800	13,800	41,400	0	0	0	0
				Total	6,500	17,000	19,500	53,000	9,100	10,500	7,700	27,300

- បានផ្តល់ធាតុចូលសម្រាប់របាយការណ៍ស្តីពីការផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣ (National Strategic Development Plan 2019-2023) ដែលសម្របសម្រួលដោយក្រសួងផែនការ។

- បានរៀបចំទម្រង់សម្រាប់ធ្វើផែនការសកម្មភាព និងថវិកាជាតិសម្រាប់ក្រសួងជាសមាជិក
- បានបញ្ចប់ការបោះពុម្ពនូវព្រឹត្តិប័ត្រទិន្នន័យ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍២០១៨ (Cambodia 2018 Snapshot on HIV)
- បានសេចក្តីព្រាងទស្សនទានស្តីការរៀបចំធ្វើសមាហរណកម្ម កម្មវិធីអេដស៍ ទៅក្នុងផែនការអភិវឌ្ឍថ្នាក់ឃុំ ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

៤. តារាងប្រឈម

- ក្រសួង ស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល មិនទាន់ ឯកភាព សហការ និងតម្លាភាពក្នុងការផ្តល់របាយការណ៍ គួលេខ ធ្វើឱ្យមានការលំបាកក្នុងបំពេញសូចនាករដែលតម្រូវ
- ភាពយឺតយ៉ាវនៃការសម្រេចលើទិន្នន័យថ្មី ធ្វើឱ្យការប្រើប្រាស់ទិន្នន័យថ្មីបន្តអូសបន្លាយ និងការប្រើប្រាស់មិនបានសុខដុមនឹងគ្នា។

៥. ជំហានបន្ត សម្រាប់ខៃបន្ទាប់

- ដាក់ឱ្យប្រើប្រាស់នៅទូទាំងប្រទេសនូវសង្ខេបទិន្នន័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០១៩ (Snapshot 2019 on HIV and AIDS in Cambodia)
- បន្តរៀបចំសន្ទានុក្រមបច្ចេកសព្ទមេរោគអេដស៍ និងជំងឺអេដស៍ ខ្មែរ-អង់គ្លេស (LEXICON OF HIV/AIDS TERMINOLOGIES Khmer-English)
- បណ្តុះបណ្តាលពង្រឹងសមត្ថភាពការងារ និងការទទួលខុសត្រូវរបស់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ
- បន្តបង្កើនទំនាក់ទំនងការងារជាមួយស្ថាប័នក្រៅ ជាតិ និងអន្តរជាតិក្នុងការអនុវត្តវិធានការទាំង៦ នៃ ស.ជ.ណ. ២១៣ និងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣
- បន្តបង្កើនទំនាក់ទំនងការងារជាមួយស្ថាប័នក្រៅ ជាតិ និងអន្តរជាតិ ឱ្យផ្តល់របាយការណ៍ និងទិន្នន័យឱ្យបានត្រឹមត្រូវ និងទាន់ពេល
- រៀបចំធ្វើសេចក្តីសម្រេចតែងតាំងសមាសភាពសមាជិកក្រុមប្រឹក្សាបច្ចេកទេសជាផ្លូវការ

- បន្តដំណើរការរៀបចំរបាយការណ៍ផ្ញើជូនអង្គការសហប្រជាជាតិ(Global AIDS Monitoring for 2019) ជូនអង្គការសហប្រជាជាតិ បានតាមការកំណត់ថ្ងៃ១៥ ខែមេសា (ខ្វះសូចនាករ ARV survey ពីWHO and STI លើក្រុម MSM, TG, EW ពី NCHADS) ខ្វះទិន្នន័យពីអ្នកពាក់ព័ន្ធដោយមូលហេតុកូវីដ សុំពន្យារ២ដង គិតពីថ្ងៃ៣១ ខែមីនា មក គឺលើកទី១៖១០ មេសា និងលើកទី២ ១៥ មេសា ដោយ UNAIDS ។
- ត្រៀមរៀបចំការងារបច្ចេកទេស សម្រាប់ផ្តល់វគ្គបណ្តុះ បណ្តាលគ្រូបង្គោលស្តីពី បរិយាកាសគាំទ្រច្បាប់ គោលនយោបាយ និងការៈកិច្ច ក្នុងការគាំទ្រឆ្លើយតបមេរោគអេដស៍ នឹងជំងឺអេដស៍ នៅថ្នាក់ក្រោមជាតិ
- រៀបចំផែនការវគ្គបណ្តុះបណ្តាលផ្ទៃក្នុង (បានស្នើសុំឯកឧត្តម លោកជំទាវអនុប្រធាន ទីប្រឹក្សា ជំនួយការ ផ្តល់នូវមុខវិជ្ជាដែលត្រូវបង្រៀនដោយបានភ្ជាប់នូវទម្រង់សម្រាប់បំពេញ កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ ២០២០)។
- ត្រៀមរៀបចំ ផែនការយុទ្ធសាស្ត្រថវិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០២១-២០២៣។
- ការងារចុះអភិបាលការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តាមបណ្តាខេត្តមួយចំនួន
- បំពេញកិច្ចការផ្សេងៗទៀត តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ។

ការរៀបចំវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពមន្ត្រី អគ្គលេខាធិការដ្ឋាន

វគ្គបណ្តុះបណ្តាល
បង្កើនសមត្ថភាពមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

លរ	មេរៀន	មន្ត្រីគោលដៅទទួលការបណ្តុះបណ្តាល (កម្រិតមន្ត្រីដែលត្រូវទទួលការបណ្តុះបណ្តាល)	ចំនួនម៉ោង	ថ្ងៃ ខែ វេលាម៉ោង	បង្រៀនដោយ (ឯកឧត្តម លោកជំទាវ អនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាន នាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ដែលមានជំនាញអាចផ្តល់ការបណ្តុះបណ្តាលបាន)
១	របៀបសរសេរបាយការណ៍				
២	របៀបធ្វើផែនការយុទ្ធសាស្ត្រ				
៣	របៀបធ្វើផែនការប្រតិបត្តិ				
៤	របៀបធ្វើផែនការថវិកា និងការអនុវត្តថវិកា				

សូមអរគុណ!